**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៦៣៥ សហវ.ប្រក.[illegible]

# ប្រកាស
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

Collection by VCAT Professional Consultant

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

# សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ជូ វិជិត្ត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាប្រធាន |
| ២. ឯកឧត្តម | **សរ សុវណ្ណា** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ជាអនុប្រធាន |
| ៣. លោកជំទាវ | **ម៉ុម ថានី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | ជាអនុប្រធាន |
| ៤. ឯកឧត្តម | **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាអនុប្រធានប្រចាំការ |
| ៥. ឯកឧត្តម | **នេត មុន្នី** | អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៦. ឯកឧត្តម | **ហោង សុខណាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧. ឯកឧត្តម | **កែន សម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៨. លោក | **រស់ តីរុណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៩. លោក | **អោម ចន** | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ១០. កញ្ញា | **ឈីន សុគន្ធា** | មន្ត្រីនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាលេខាធិការ |
| ១១. កញ្ញា | **ស៊ីន សុខពៅ** | មន្ត្រីនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាលេខាធិការ |

**ប្រការ ២.-**

គណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានភារកិច្ច ដូចខាងក្រោម ÷

- បង្កើតបញ្ជីរាយនាមឈ្មោះតំបន់ ឬខណ្ឌ នៃរាជធានី និងក្រុង ស្រុក នៃខេត្ត ដែលមានដីត្រូវជាប់ពន្ធ
- កំណត់ប្រចាំឆ្នាំនូវតម្លៃដីក្នុងមួយម៉ែត្រក្រឡា
- ផ្តល់មតិចំពោះរឿងវិវាទ។

**ប្រការ ៣.-**

គណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានសិទ្ធិចាត់តាំងអនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅតាមរាជធានី-ខេត្ត ដែលមានអភិបាលរាជធានី-ខេត្ត ឬតំណាងជាប្រធាន សម្រាប់ជំនួយការក្នុងការអនុវត្តភារកិច្ចខាងលើ។

Collection by VCAT Professional Consultant

**ប្រការ ៤.-**

គណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញការងារ និងភារកិច្ចរបស់ខ្លួន។

**ប្រការ ៥.-**

ប្រកាសលេខ ០៦៧ សហវ.ប្រក.ពដ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.-**

សមាសភាពដូចមានរាយនាមក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន ÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- សាលារាជធានី-ខេត្ត "ដើម្បីសហការអនុវត្ត"
- ដូចប្រការ ១ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Collection by VCAT Professional Consultant